# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការពារជាតិ**

## សូមគោរពជូន

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

នៅក្នុងឱកាសដ៏ឧត្តុង្គឧត្តម ប្រពៃថ្លៃថ្លាដែល **សម្តេចតេជោ** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទទួលសញ្ញាបត្របណ្ឌិតកិត្តិយស ផ្នែកអក្សរសាស្ត្រពីសាកលវិទ្យាល័យក្វាងស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១៥ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាននៃកងយោធពលខេមរភូមិន្ទទាំងអស់ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវមនោសញ្ចេតនា សោមនស្សរីករាយ ឥតឧបមា និងអបអរសាទរយ៉ាងក្លៀវក្លាបំផុតចំពោះ **សម្តេចតេជោ** ដែលទទួលបាននូវសញ្ញាបត្របណ្ឌិតកិត្តិយស ផ្នែកអក្សរសាស្ត្រ ពីសាធារណរដ្ឋប្រជាមានិតចិន គឺពិតជាផ្តល់នូវមហាកិត្តិយស ដ៏ឧត្តុង្គឧត្តមសម្រាប់ **សម្តេច** និងក្រុមគ្រួសាររបស់ **សម្តេច** ក៏ដូចជាសម្រាប់ប្រទេសជាតិ និងប្រជាជនកម្ពុជាទាំងមូល និងជាការឆ្លើយតបយ៉ាងស័ក្តិសមបំផុតចំពោះស្នាដៃរបស់ **សម្តេច** ក្នុងការខិតខំប្រឹងប្រែងអភិវឌ្ឍន៍ប្រទេសជាតិលើគ្រប់វិស័យ ជាពិសេសវិស័យអប់រំនិងការប្រឹងប្រែងកែលម្អជីវភាពប្រជាជន ហើយ **សម្តេច** គឺជាថ្នាក់ដឹកនាំប្រកបដោយគតិបណ្ឌិតក្នុងការបង្រួបបង្រួមសន្តិភាព និងជាថ្នាក់ដឹកនាំកសាងប្រទេសដែលមានទស្សនវិស័យដឹកនាំផ្ទាល់ ធ្វើអោយមានការផ្លាស់ប្តូរជាបន្តបន្ទាប់ នាំប្រទេសជាតិទាំងមូលរួចចាកផុតពីសង្គ្រាម មានសន្តិភាព និងការអភិវឌ្ឍន៍រីកចំរើនលើគ្រប់វិស័យ។

ការទទួលបាននូវសញ្ញាបត្របណ្ឌិតកិត្តិយសដ៏វិសេសវិសាលនេះ គឺពិតជាបានបង្ហាញយ៉ាងស័ក្តិសមចំពោះពលិកម្មដ៏ថ្លៃថ្លារបស់ **សម្តេច** ដែលជានិច្ចកាល **សម្តេច** បានបូជាកម្លាំងកាយចិត្តនិងប្រាជ្ញាស្មារតី ដើម្បីបម្រើឧត្តមប្រយោជន៍ជាតិមាតុភូមិនិងប្រជាពលរដ្ឋ ។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវការគោរពជូនពរចំពោះ **សម្តេចតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងបុត្រាបុត្រី ចៅប្រុស ចៅស្រី ទាំងអស់ សូមមានសុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ បញ្ញាញាណភ្លឺថ្លា ត្រចះត្រចង់ ដើម្បីបន្តដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ប្រកបដោយវឌ្ឍនភាព និងវិបុលភាពតរៀងទៅ ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី ស្តីទី**

នាយឧត្តមសេនីយ៍ **ចាយ សាំងយុន**